# ធ្វើការជាមួយអ្នកដែលគេយកចិត្តទុកដាក់តិចតួច



*នៅក្នុងពិភពលោក មានកុមារជាច្រើនដែលពុំមានអាហារទទួលទានគ្រប់គ្រាន់ គ្មានការអប់រំមូលដ្ឋាន គ្មានជម្រកសុវត្ថិភាព និងគ្មានការការពារពីអំពើហឹង្សា និងការរំលោភបំពាន។ នេះមិនមែនជារឿងគួរឲ្យសោកស្តាយនោះទេ តែវាជារឿងខុសទាំងស្រុង។ យោងតាមអនុសញ្ញាស្តីពីសិទ្ធិកុមារ កុមារទាំងអស់មានសិទ្ធិទទួលបានអាហារ ការអប់រំ ការស្នាក់នៅ ការការពារ និងសិទ្ធិជាមូលដ្ឋានដទៃទៀត។ នេះរាប់បញ្ចូលទាំងកុមារនៅក្នុងប្រទេសកម្ពុជាផងដែរ ពីព្រោះរាជរដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខាលើអនុសញ្ញាស្តីពីសិទ្ធិកុមាររួចហើយ។ រាជរដ្ឋាភិបាលកម្ពុជា កំពុងធ្វើការឆ្ពោះទៅរកការសម្រេចអនុសញ្ញានេះ ហើយដំណាក់កាលមួយគឺការបង្កើតគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ/សង្កាត់(គ.ក.ន.ក)នៅទូទាំងប្រទេស។ ក្នុងអំឡុងពេលពីខែឧសភាដល់ខែកក្កដា អង្គការអាយស៊ីស៊ីបានធ្វើការសិក្សាអំពីដំណើរការនៃរចនាសម្ព័ន្ធ គ.ក.ន.ក និងលទ្ធភាពក្នុងការសហការ។*

គណៈកម្មាធិការធ្វើគម្រោងអាយស៊ីស៊ី បានធ្វើការសិក្សានៅតាមខេត្តចំនួនបីខុសៗគ្នានៅថ្នាក់ឃុំស្រុក និងខេត្តដោយផ្តោតលើកុមារអ្នកផ្តល់ព័ត៌មានផ្សេងៗត្រូវបានសម្ភាសរួមទាំងកុមារ និងឪពុកម្តាយ និងអ្នកថែទាំផងដែរ។

កុមារ និងក្មេងជំទង់ ដឹងថាជីវភាពរស់នៅរបស់ពួកគេមិនល្អប្រសើរឡើយ ហើយបានបង្ហាញពីតម្រូវការចង់ឲ្យ គ.ក.ន.ក ជួយអន្តរាគមន៍ដល់ពួកគេ។ សំណូមពរខ្លះៗរបស់ពួកគេ គឺកុំឲ្យមានកុមារឈប់រៀន ឬកុំធ្វើឲ្យកុមារបោះបង់ចោលសាលារៀន ផ្តល់សាលារៀនល្អជាមួយការអប់រំ និងបរិក្ខាល្អ ជួយបញ្ឈប់អំពើហិង្សាក្នុងគ្រួសារ និងប្រឆាំងការរំលោភបំពានលើកុមារ ដូចជាការរំលោភបំពានផ្លូវភេទ និងកម្លាំងពលកម្មជាដើម។

ឪពុកម្តាយ និងអ្នកមើលថែបានសម្តែងនូវការកោតសរសើរចំពោះការងាររបស់ គ.ក.ន.ក និងការចូលរួមនៅក្នុងសហគមន៍របស់ពួកគាត់។ នៅតាមឃុំមួយចំនួន គ.ក.ន.ក កំពុងធ្វើការលើកកំពស់ការយល់ដឹងអំពីសិទ្ធិកុមារ និងអាហារូបត្ថម្ភសម្រាប់កុមារ។ ឪពុកម្តាយ និងអ្នកថែទាំ បានបញ្ជាក់ពីតម្រូវការនៃវត្តមានរបស់ គ.ក.ន.ក ជាពិសេសនៅក្នុងការធ្វើរបាយការណ៍ទៅកាន់អាជ្ញាធរជាន់ខ្ពស់ នៅពេលការរំលោភបំពានផ្លូវភេទកើតឡើងចំពោះកុមារ ឬស្ត្រី។ ដូចគ្នានេះដែរ គ.ក.ន.ក មានតួនាទីសំខាន់ក្នុងការគាំទ្រមត្តេយ្យសាលានៅក្នុងសហគមន៍សម្រាប់ជាប្រយោជន៍ដល់កុមារតូចៗ។

ជាងនេះទៅទៀតតាមរយៈការសិក្សានេះ អាយស៊ីស៊ី រៀនបានថាបុគ្គលិក គ.ក.ន.ក មានចំណង់ចិត្ត និងទឹកចិត្តចង់ធ្វើឲ្យជីវភាពរស់នៅ និងផ្តល់បង្កបង្កើតកាលៈទេសៈកាន់តែប្រសើរឡើងសម្រាប់កុមារ និងស្ត្រីនៅក្នុងសហគមន៍។ ទោះជាយ៉ាងណាក៏ដោយ ពេលខ្លះបុគ្គលិកមានបញ្ហាប្រឈមក្នុងការបំពេញភារកិច្ចដោយសារតែចំណេះដឹង និងធនធានមានកម្រិត។ វិសាលភាពនៃបញ្ហាសង្គមដែលប៉ះពាល់ដល់កុមារនិងស្ត្រីមានទំហំធំ ប៉ុន្តែរាជរដ្ឋាភិបាលកំពុងស្វែងរកការផ្តល់ចំណេះដឹងថ្មីៗដល់ពួកគាត់ តាមផ្នែកបច្ចេកទេសផ្សេងៗ។

ផ្នែកមួយដែល គ.ក.ន.ក បានចូលរួម គឺធានាថាកុមារត្រូវបានផ្តល់ជូននូវសំបុត្រកំណើតនៅពេលពួកគេកើតមក។ ឪពុកម្តាយខ្លះ មិនយកចិត្តទុកដាក់ក្នុងការផ្តល់ឲ្យកូនៗនូវលក្ខណៈស្របច្បាប់នេះទេ ប៉ុន្តែ គ.ក.ន.ក ផ្តល់អាទិភាពលើបញ្ហានេះ ដើម្បីបំពេញសិទ្ធិដល់កុមារ។

អង្គការអាយស៊ីស៊ី មានគំនិតផ្តួមផ្តើមសិក្សាពី គ.ក.ន.ក នេះ ដោយសារតែអាយស៊ីស៊ី មានចំណាប់អារម្មណ៍ក្នុងការបង្កើនការងាររបស់ខ្លួនលើការលើកកម្ពស់ និងធានាថាកុមារត្រូវបានផ្តល់សិទ្ធិស្របច្បាប់របស់ពួកគេ។ ទោះជាយ៉ាងនេះក្តី ដើម្បីទទួលបាននូវភាពជោគជ័យជាវិជ្ជមាន អាយស៊ីស៊ី ជឿជាក់ថាការងារនេះធ្វើទៅបាន លុះត្រាណាមានកិច្ចសហការជិតស្និទ្ធជាមួយអាជ្ញាធរមូលដ្ឋាន។ អាយស៊ីស៊ី នឹងស្វែងយល់បន្ថែមទៀតអំពីរបៀបនៃការកិច្ចសហការជាមួយ គ.ក.ន.ក ដើម្បីឧត្តមប្រយោជន៍សម្រាប់កុមារកម្ពុជា។

កាលបរិច្ឆេទ៖ កញ្ញា ២០១៧